Searching for the truth MEMORY, JUSTICE & HEALING
"...a society cannot know itself if it does not have an accurate memory of its own history."

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
ល.រ : ២៨៣ **MoEYS/Adm**

សុន្ទរកថា
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
ស្តីពីការសម្ពោធការរៀបចំរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹត
សាលតាំងពិព័រណ៍ ហ្សាហា ហាឌីដ ទីក្រុងឡុងដ៏
ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤

សួស្តី លោកស្រី ហ្សាហា ហាឌីដ ភ្ញៀវកិត្តិយស លោក លោកស្រី អ្នកនាង កញ្ញា ជាទីគោរព។ តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមសម្តែងនូវសេចក្តីពេញចិត្តចំពោះវត្តមានរបស់ភ្ញៀវកិត្តិយស ដែលមានវត្តមាននៅក្នុងកម្មវិធីសម្ពោធ ការរៀបចំរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹត ដែលមានភាពអស្ចារ្យ និងបណ្តុះគំនិតថ្មីនេះ។ ខ្ញុំមានគម្រោងចូលរួមក្នុងកម្មវិធីដ៏សំខាន់នេះ ប៉ុន្តែដោយសារតែខ្ញុំមានកាតព្វកិច្ចបន្ទាន់នៅក្នុងប្រទេសកម្ពុជាធ្វើឱ្យខ្ញុំមិនអាចចូលរួមដោយផ្ទាល់បាន។

ដូចលោក លោកស្រី បានជ្រាបហើយថា ប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍតូចមួយដែលទើបតែងើបចេញពីការគ្រប់គ្រងរបស់អាណានិគមដ៏យូរលង់និងកេរដំណែលដ៏ឃោរឃៅនៃរបបខ្មែរក្រហម។ ទោះបីជា សេដ្ឋកិច្ចរបស់យើងមានភាពរីកចម្រើន ប៉ុន្តែ ប្រជាជនកម្ពុជាជាច្រើន នៅតែបន្តរស់នៅក្នុងភាពក្រីក្រ។ រាជរដ្ឋាភិបាលមានចំណូលមិនគ្រប់គ្រាន់សម្រាប់ឆ្លើយតបនឹងតម្រូវការចំពោះមុខជាច្រើន ដែលចាំបាច់ត្រូវតែដោះស្រាយ។ តម្រូវការមួយក្នុងចំណោមនោះគឺ អប់រំយុវវ័យជំនាន់ក្រោយអំពីប្រវត្តិសាស្រ្ត និងមេរៀនពីរបបខ្មែរក្រហមនិងកេរដំណែលដ៏ខ្មៅងងឹតនេះ។យើងចាំបាច់ត្រូវតែពង្រីកការអប់រំនេះឱ្យធំទូលាយ និងរួមបញ្ចូលទាំងវប្បធម៌ និងប្រវត្តិសិល្បៈដ៏រុងរឿងរបស់ប្រទេសកម្ពុជា។ អាស្រ័យហេតុនេះ ក្រសួងអប់រំ

www.cambodiasri.org

យុវជន និង កីឡា មានឱកាសដែលបានសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបង្កើតកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍ ដ៏មានប្រសិទ្ធភាពនៅក្នុងសាលារៀន ទូទាំងប្រទេសកម្ពុជា និងនៅតាមតំបន់ដាច់ស្រយាល។

ការសម្ពោធការរៀបចំរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹត ដែលជាគម្រោងសំខាន់ថ្មីនេះ តំណាងឱ្យកិច្ចសហប្រតិបត្តិការដំណាក់កាលទី២ និងជាបន្តបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា។ ខ្ញុំមានសេចក្តីសោមនស្សរីករាយនឹងជម្រាបជូនថា រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនឹងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ផ្តល់ដីដ៏ធំមួយកន្លែង នៅទីប្រជុំជននៃទីក្រុងភ្នំពេញ សម្រាប់សាងសង់វិទ្យាស្ថានស្លឹករឹត។ ដីដ៏មានតម្លៃមួយកន្លែងនោះ មានទំហំធំល្មម សម្រាប់រៀបចំ និងបង្កើតបរិយាកាសដ៏ស្រស់ស្អាតនៅជុំវិញអគារ។ អគារដ៏ពិសេស និងទីធ្លាដ៏ស្អាតនេះនឹងដើរតួជាកន្លែងរំឭកដល់ជនរងគ្រោះ ដែលនៅរស់រានមានជីវិត និងអ្នកដែលបានស្លាប់បាត់បង់ជីវិតដោយអំពើប្រល័យពូជសាសន៍។

រាជរដ្ឋាភិបាលកម្ពុជា នឹងសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធានាថា វិទ្យាស្ថានស្លឹករឹត នឹងទទួលបានការទទួលស្គាល់ជាអន្តរជាតិថាជា វិទ្យាស្ថានអប់រំអំពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្សនាំមុខគេនៅសតវត្សរ៍២១។ នេះមិនមែនជាសកម្មភាពធម្មតាទេ ប៉ុន្តែជាសកម្មភាពដ៏សំខាន់ដើម្បីរំឭកដល់ជនរងគ្រោះនៃរបបខ្មែរក្រហមដ៏សាហាវឃោរឃៅ។ យើងសូមស្វាគមន៍ និងអរគុណចំពោះការគាំទ្រ និងអរគុណដល់សហគមន៍អន្តរជាតិ ដែលធ្វើការជាមួយគ្នាដើម្បីសម្រេចបានគោលដៅនេះ។ យើងរំពឹងថា វិទ្យាស្ថានស្លឹករឹត នឹងសហការជាមួយប្រទេសផ្សេងទៀតនៅតំបន់អាស៊ាន ដើម្បីផ្សព្វផ្សាយ និងស្វែងរកវិធីសាស្ត្រ ដើម្បីបញ្ចប់ការរំលោភសិទ្ធិមនុស្សដោយក្រុមហិង្សា និងក្រុមជ្រុលនិយម ទាំងនៅក្នុង និងនៅក្រៅជួររដ្ឋាភិបាល។ ឧក្រិដ្ឋកម្មសង្គ្រាមដ៏ឃោរឃៅ ការរំលោភសេពសន្ថវៈទៅលើស្ត្រីនិងកុមារ ការសម្លាប់ និងការធ្វើទារុណកម្មទៅលើជនស្លូតត្រង់កំពុងតែកើតឡើងជាបន្តបន្ទាប់នៅប្រទេសមួយចំនួន ដូចជា ភូមា ស៊ីរី អ៊ីរ៉ាក់ សាធារណរដ្ឋអាហ្វ្រិកកណ្តាល ស៊ូដង់ខាងត្បូង លីប៊ី នីសេរីយ៉ា សូម៉ាលី អ៊ុយក្រែន កាហ្សា និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ មនុស្សមានភាពឆ្លាតវៃជាងគេដែលអាចបង្កើតលោក

ដូច្នេះ មិនមានហេតុផលណាមួយដែលធ្វើឱ្យមនុស្សធ្វើសកម្មភាពបំផ្លាញខ្លួនឯងដែលបំផ្លាញដល់មនុស្សជាតិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សនោះទេ។

យើងសង្ឃឹមថា ជាមួយនឹងការបង្កើតវិទ្យាស្ថានស្លឹករឹត ប្រទេសកម្ពុជានឹងដើរតួនាទីជាអ្នកដឹកនាំមនុស្សនៅក្នុងពិភពលោកតាមរយៈការបង្ហាញពីការលំបាកនិងមេរៀនដ៏ឈឺចាប់ និងសារសំខាន់ក្នុងការចងក្រងឯកសារ និងផ្សព្វផ្សាយដែលប្រកបដោយវិជ្ជាជីវៈ និងភាពសមរម្យ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ យើងស្នើសុំ និងទទួលស្គាល់ការគាំទ្រជាសមូហភាព និងអំពើល្អរបស់អ្នកទាំងអស់គ្នា។

អរគុណ។

បណ្ឌិត ហង់ ជួន ណារ៉ុន
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាសាស្ត្រាចារ្យច្បាប់អន្តរជាតិ
ព្រះរាជាណាចក្រកម្ពុជា